មាត្រា២ : នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះរាជហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ កញ្ញា ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

* * *

# II ឱស្ថីការគណៈរដ្ឋមន្ត្រី

## ១ អនុក្រឹត្យ

*រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៤*

អនុក្រិត្យ

អនុក្រឹត្យ លេខ ៥៤ អនក្រ

ស្ដីពីការផ្ដល់ប្រាក់រង្វាន់ភ្ជាប់ជាមួយប័ណ្ណសរសើរ

និងលិខិតសរសើរ របស់ក្រសួងការពារជាតិ និង អគ្គសេនាធិការ

កងយោធពលខេមរភូមិន្ទ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា

ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤

**សំរេច**

មាត្រា១ : កងឯកភាព នាយទាហាន នាយទាហានរង និង ពលទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានស្នាដៃល្អក្នុងភារកិច្ចការពារជាតិហើយ ត្រូវបានទទួលប័ណ្ណសរសើរ ឬ លិខិតសរសើររបស់ក្រសួងការពារជាតិ និង អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ នឹង ត្រូវបានទទួលនូវទឹកប្រាក់រង្វាន់ភ្ជាប់ជាមួយ ដូចមានកំណត់ចំនួនខាងក្រោមៈ

-ប័ណ្ណសរសើរជូនកងឯកភាពភ្ជាប់ដោយទឹកប្រាក់៣៥.០០០៛ ( សាមសិបប្រាំពាន់រៀល )

-លិខិតសរសើរជូនកងឯកភាពភ្ជាប់ដោយទឹកប្រាក់.២០.០០០៛(ម្ភៃពាន់រៀល)

-ប័ណ្ណសរសើរជូនបុគ្គលភ្ជាប់ដោយទឹកប្រាក់. ១៥.០០០ ៛(ដប់ប្រាំពាន់រៀល)

-លិខិតសរសើរជូនបុគ្គល ភ្ជាប់ដោយទឹកប្រាក់ ១០.០០០៛ ( ដប់ពាន់រៀល )

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិនិង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១

ព្រះហស្តលេខា និងត្រា

នរោត្តម រណឫទ្ធិ

* * *